# វិធីដាក់ពាក្យសុំចូលរៀននៅវិទ្យាល័យ សម្រាប់
# សិស្ស ពិការ 504 Plans និងសិស្សដែលត្រូវរៀនភាសាអង់គ្លេស

### ចំណុចសំខាន់ៗសម្រាប់មាតាបិតា

នៅពេលកូនលោកអ្នកដាក់ពាក្យសុំចូលរៀននៅវិទ្យាល័យទទួលសិស្ស សម្រាប់**កម្មវិធី CTC ដែលមានលក្ខណៈសម្បត្តិពិសេស និង/ឬ ទូទាំងក្រុង** សូមធ្វើតាមចំណុចសំខាន់ៗ និងងាយស្រួលទាំងនេះ ដើម្បីឲ្យមានការប្រព្រឹត្តទៅដោយសម្រួល៖

- ពិភាក្សាជាមួយកូនលោកអ្នកអំពី៖
  - ❑ សាលាដល់ទៅប្រាំ ដែលត្រូវតាមសេចក្តីត្រូវការ និងចំណាប់អារម្មណ៍ របស់កូនលោកអ្នក
  - ❑ ការត្រៀមខ្លួនសម្រាប់ ការសម្តែងសាកល្បង ការធ្វើសម្ភាសន៍ និងកម្រងស្នាដៃ (portfolios)
  - ❑ ពេលកំណត់សម្រាប់ ការសម្តែងសាកល្បង ការធ្វើសម្ភាសន៍ និងកម្រងស្នាដៃ

- បំពេញ **លិខិតដាក់ពាក្យសុំផ្លាស់ប្តូរវិទ្យាល័យដោយស្ម័គ្រចិត្ត** ហើយប្រគល់ឲ្យទៅអ្នកផ្តល់ឱវាទរបស់កូនលោកអ្នកវិញ។

**សម្រាប់សិស្ស ពិការ ឬ 504 Plans**

- បើសិនជាចង់ សូមស្នើសុំជួបប្រជុំជាមួយក្រុម IEP ហើយពិភាក្សាអំពីអ្វីៗខាងក្រោមនេះ សម្រាប់កូនរបស់លោកអ្នក៖
  - ❑ ការរីកចម្រើននៃការសិក្សា
  - ❑ អាកប្បកិរិយា
  - ❑ ឯកសារ វត្តមានអវត្តមាន និងការមករៀនទាល់ពេលវេលា
  - ❑ ពិន្ទុនៃការប្រឡង PSSA
  - ❑ ជំនួយ និងសេវា បន្ថែម
  - ❑ បរិយាកាសដែលមិនសូវតឹងតែង (LRE)
  - ❑ សាលា និងកម្មវិធី ដែលទាក់ទាញចំណាប់អារម្មណ៍របស់ពួកគេ
  - ❑ លក្ខណវិនិច្ឆ័យនៃការទទួលសិស្ស
  - ❑ ការដែលអាចលើកលែង ចំពោះលក្ខណវិនិច្ឆ័យនៃការទទួលសិស្ស
- សុំលិខិតគាំទ្រពីសាលា និងពីអង្គការនានានៅក្នុងសហគមន៍

**សម្រាប់សិស្សដែលត្រូវការរៀនភាសាអង់គ្លេស**

- បើសិនជាចង់ សូមស្នើសុំជួបប្រជុំជាមួយក្រុម LeGare នៅតាមសាលា រួមទាំងគ្រូ ESOL ហើយពិភាក្សាអំពីអ្វីៗខាងក្រោមនេះ សម្រាប់កូនរបស់លោកអ្នក៖
  - ❑ ការរីកចម្រើននៃការសិក្សា
  - ❑ ពិន្ទុ ដើម្បីឲ្យដឹងប្រាកដថាស្របតាម Can-Do Descriptors
  - ❑ អាកប្បកិរិយា
  - ❑ ឯកសារ វត្តមានអវត្តមាន និងការមករៀនទាន់ពេលវេលា
  - ❑ ពិន្ទុនៃការប្រឡង PSSA
  - ❑ សាលា និងកម្មវិធី ដែលទាក់ទាញចំណាប់អារម្មណ៍របស់ពួកគេ
  - ❑ លក្ខណវិនិច្ឆ័យនៃការទទួលសិស្ស
  - ❑ ការដែលអាចលើកលែង ចំពោះលក្ខណវិនិច្ឆ័យនៃការទទួលសិស្ស
- សុំលិខិតគាំទ្រពីសាលា និងពីអង្គការនានានៅក្នុងសហគមន៍
- ស្នើសុំការបកប្រែ ផ្ទាល់មាត់ និងតាមការសរសេរ

**ការពិនិត្យឡើងវិញដោយមិនលម្អៀង**

- បើសិនជាគេ**មិនជ្រើសរើស**កូនលោកអ្នកឲ្យចូលក្នុង **កម្មវិធី CTC** វិទ្យាល័យទទួលសិស្សដែល មានលក្ខណៈសម្បត្តិពិសេស និង/ឬ ទូទាំងក្រុង ណាមួយ ដែលពួកគេបានដាក់ពាក្យសុំចូលទេនោះ លោកអ្នក**នឹង**ទទួលលិខិតនៅ**និទាឃរដូវ ឆ្នាំ២០១៤** ដែលពន្យល់ពីវិធីស្នើសុំ **ការពិនិត្យឡើងវិញដោយមិនលម្អៀង។**

បើសិនជាលោកអ្នក**មិនចង់ឲ្យកូនចូលរួម**ក្នុងការគាំទ្រវិធីដាក់ពាក្យសុំចូលរៀននៅវិទ្យាល័យរបស់កម្មវិធី LeGare ទេ សូមបំពេញ៖ **សេចក្តីថ្លែងការណ៍អំពីការលះបង់សិទ្ធិចូលរួមក្នុងកម្មវិធី LEGARE**

- ទាក់ទងអ្នកផ្តល់ឱវាទរបស់កូនលោកអ្នក ដើម្បីជ្រាបព័ត៌មានបន្ថែម